## សហនិមិត្តហេតុនៃការអង្រួន់ទារក

ការអង្រួន់ទារកឬក្មេងតូច - ទោះជាមួយរយៈពេលខ្លីក៏ដោយ-ក៏អាចបណ្តាលឲ្យមានរបួស ដូចជា:

- ខ្វាក់ភ្នែក
- ខូចខួរក្បាល
- បាក់ឆ្អឹង
- មិនគ្រប់ទឹក
- ស្តាប់លែងសូវឮ
- អសមត្ថភាពក្នុងការរៀនសូត្រឬនិយាយស្តី
- ប្រកាច់
- ដំណើរកម្រើកលែងបាន
- ហើយក៏បណ្តាលឲ្យស្លាប់

ទារកនិងកូនក្មេងមានក្បាលធំជាងរាងកាយរបស់ពួកគេ។ នៅពេលអ្នកអង្រួន់ទារក វាបណ្តាលឲ្យក្បាលទារកបត់ទៅមុខមកក្រោយ។ ដូច្នេះអាចបណ្តាលឲ្យដាច់សសៃឈាមក្នុងខួរក្បាលនិងភ្នែកហើយចេញឈាម ហើយធ្វើឲ្យខូចខាតដល់កោសិកាដែលនៅក្នុងខួរក្បាល។ ដូចេះហើយបានជាការអង្រួន់ទារកឬកូនក្មេងអាចបណ្តាលឲ្យមានគ្រោះថ្នាក់ធ្ងន់ធ្ងរហើយជាទូទៅធ្វើឲ្យពិការ។ របួសទាំងនេះហៅថា សហនិមិត្តនៃការអង្រួន់ទារក។ ការអង្រួន់ទារកត្រូវគិតថាជាអំពើធ្វើបាបដល់ទារក។

ការយំស្រែករបស់ទារកគឺជាមធ្យោបាយរបស់ទារកដើម្បីប្រាប់ឲ្យដឹង:
គន្លឹសធ្វើឲ្យទារកឈប់យំ។ ត្រូវមានការអត់ធ្មត់ហើយរកមើលថាតើទារកត្រូវការអ្វី។ សាកធ្វើអ្វីៗដូចខាងក្រោមនេះ។

- កុំឆេវឆាវ
- បំពៅទារក
- លើកទារកពរ
- មើលថាតើទារកក្តៅពេកឬត្រជាក់ពេក
- ទះខ្នោងទារកឲ្យភើ
- ឆែកមើលកន្ទប
- ឲ្យក្បាលដោះបៀមឬប្រដាប់លេង

បើអ្វីៗខាងលើទាំងប៉ុន្មានមិនជួយ:

- យកទារកទៅបន្ទប់ដែលស្ងៀមស្ងាត់
- ដាក់ទារកក្នុងឡានបើកលេងឬដាក់ក្នុងរទេះរុញក្មេង
- ដាក់ទារកក្នុងគ្រែសម្រាប់ទារកគេង
- បីទារកដាក់លើទ្រូងរបស់អ្នកហើយដើរទៅដើរមក
- បើអ្វីៗទាំងអស់នេះមិនជួយឲ្យទារកឈប់យំទេ ទូរស័ព្ទទៅវេជ្ជបណ្ឌិតមើលទារក

បើទារកយំ ហើយធ្វើឲ្យរំខានដល់អ្នក ចូរដាក់ទារកឲ្យគេងផ្ងាពោះក្នុងគ្រែទារក ហើយអ្នកទៅបន្ទប់ផ្សេងទៀត។ សូមសម្រាកនៅបន្ទប់នោះមួយស្របក់សិន។

- ដកដង្ហើមយឺតៗហើយវែងៗ
- ទូរស័ព្ទទៅមិត្តភ័ក្រឬញាតិមិត្តដើម្បីនិយាយ
- ហាត់ប្រាណនៅជិតទារក
- ស្តាប់ចំរៀង
- អានសៀវភៅ
- សុំឲ្យគេជួយ

ត្រឡប់ទៅមើលទារកវិញក្នុងកំឡុងពេល៥ទៅ១០នាទី។ សូមចាំថា ជួនកាលទារកនៅតែយំ ទោះជាអ្នកធ្វើអ្វីក៏ដោយ។
បើអ្នកគិតថាមានគេអង្រួន់ទារករបស់អ្នក. . . សូមទៅកាន់កន្លែងភាពអាសន្ននៅមន្ទីរពេទ្យណាដែលនៅជិតបំផុត។
សញ្ញានៃរបួសដែលអាចបណ្តាលមកពីការអង្រួន់មាន:

- មិនធម្មតា ពិបាក ឬឈប់ដកដង្ហើម
- ខឹងខ្លាំងមែនទែន
- ប្រកាច់ឬក្អួត
- ញ័រជើងដៃ
- ទន់ដៃទន់ជើង
- ដេកមិនក្រោក
- ដេកមិនភ្ញាក់ឬមិនយកចិត្តទុកដាក់ពេលមានសំឡេងឬដូចជាបាត់ស្មារតីឬដូចជាស្លាប់

ចែកពត៌មាននេះទៅអ្នកដែលមើលថែកូនរបស់អ្នក។

សូមមេត្តាកុំអង្រួន់ទារក!